# តារាងស្តីពីព័ត៌មានរបស់គម្រោង

លេខPIP : 1440

(សម្រាប់បំពេញដោយក្រសួងផែនការ)

## ព័ត៌មានមូលដ្ឋានអំពីគម្រោង

ផ្នែក ក

*(ត្រូវបំពេញគ្រប់ចំណុចទាំងអស់)*

១. ឈ្មោះគម្រោង : គម្រោងសាងសង់ប្រព័ន្ធស្រោចស្រពទំនើបនៅតាមសហគមន៍កសិកម្ម

២. កាលបរិច្ឆេទគម្រោង

| | |
|---|---|
| កាលបរិច្ឆេទចាប់ផ្តើមគម្រោង | 01/01/20 |
| កាលបរិច្ឆេទបញ្ចប់គម្រោង | 31/12/24 |

៣. ចំណាយគម្រោងសរុប $7,700,000

៤. ស្ថាប័នទទួលខុសត្រូវ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

| | |
|---|---|
| RESPONSIBLE UNIT | General Directorate of Agriculture |
| អង្គភាពទទួលខុសត្រូវ | អគ្គនាយកដ្ឋានកសិកម្ម |

៥. ស្ថានភាពគម្រោង គម្រោងដែលបានបញ្ចប់

ព័ត៌មានលម្អិតអំពីគម្រោង

៦. ប្រភេទគម្រោង ៖ គម្រោងវិនិយោគជាទុន

៧. ប្រភពហិរញ្ញប្បទាន៖ ថវិកាជាតិ

៨. មុំនៃគោលនយោបាយក្នុងយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី១ ដែលគម្រោងស្ថិតនៅ

មុំទី២- ការលើកស្ទួយសហគ្រាសធុនមីក្រូ តូច និងមធ្យម ធុរកិច្ចថ្មី សហគ្រិនភាព និងការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ

៩. ការចូលរួមចំណែករបស់គម្រោងក្នុងការសម្រេចបានគោលនយោបាយអាទិភាពខាងលើ

គម្រោងរួមចំណែកដល់ការបង្កើនផលិតភាព និងផលិតកម្មដំណាំបន្លែមានគុណភាពសម្រាប់ការផ្គត់ផ្គង់ក្នុងស្រុក និងបង្កើនប្រាក់ចំណូលសម្រាប់សមាជិកសហគមន៍កសិកម្ម ដែលជាសហគ្រាសសេដ្ឋកិច្ចជនបទ។

## ១០. ការគាំទ្រដល់គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា

តើគម្រោងនេះគាំទ្រដល់ការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាដែរឬទេ? គាំទ្រ

១១. វិស័យ (សូមប្រើវិស័យ អនុវិស័យ ដែលមានចែងក្នុងផ.យ.អ.ជ. )

| | |
|---|---|
| កសិកម្ម និងការគ្រប់គ្រងដីធ្លី | Research and Extension Services |
| | Crop irrigation |

១២. ទីតាំងអនុវត្តគម្រោង (ពិពណ៌នាពីទីតាំងដែលត្រូវអនុវត្តគម្រោង)

ព្រៃវែង, ក្រចេះ, កំពង់ស្ពឺ, សៀមរាប, កំពង់ធំ, កណ្ដាល, កំពង់ចាម, កំពង់ឆ្នាំង, ត្បូងឃ្មុំ , បាត់ដំបង, ពោធិ៍សាត់, ឧត្ដរមានជ័យ,

១៣. គោលបំណងរបស់គម្រោង (ពិពណ៌នាគោលបំណងចម្បងៗរបស់គម្រោង)

គម្រោងសាងសង់ហេដ្ឋារចនាសម្ព័ន្ធស្រោចស្រពលើដំណាំបន្លែ មានគោលបំណងសំខាន់ៗ ដូចខាងក្រោម៖

- អភិវឌ្ឍប្រព័ន្ធស្រោចស្រពទំនើបសម្រាប់ផលិតកម្មដំណាំបន្លែប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផល
- ផ្គត់ផ្គង់ទឹកសម្រាប់ស្រោចស្រពដំណាំបន្លែបានពេញមួយឆ្នាំ និងចំណេញពេលវេលានិងកម្លាំងពលកម្មក្នុងការស្រោចស្រពបន្លែ (មានពេលវេលាច្រើនធ្វើកិច្ចការផ្សេងៗ)
- បង្កើនការដាំដុះបន្លែពី៤-៦ដង/ឆ្នាំ

នៅតាមសហគមន៍កសិកម្មដែលមានសក្ដានុពលនិងសមត្ថភាពគ្រប់គ្រាន់ដែលអាចផ្គត់ផ្គង់បន្លែសុវត្ថិភាពស្របតាមតម្រូវការទីផ្សារក្នុងស្រុក

- បង្កើនប្រាក់ចំណូលរបស់កសិករកាន់តែច្រើនសម្រាប់ទ្រទ្រង់ជីវភាពប្រចាំថ្ងៃ តាមរយៈការកាត់បន្ថយការចំណាយថវិកាលើការបូមទឹកដោយប្រើម៉ាស៊ីនបូមទឹក ការចំណាយពេលវេលានិងកម្លាំងពលកម្មក្នុងផលិតកម្មដំណាំបន្លែ។

១៤. ការពិពណ៌នាអំពីគម្រោង (ពិពណ៌នាអំពីសមាសភាគទាំងអស់របស់គម្រោង)

គម្រោងនេះ បានសាងសង់ហេដ្ឋារចនាសម្ព័ន្ធស្រោចស្រពនៅតាមបណ្ដាសហគន៍កសិកម្មក្នុងខេត្តចំនួន ១២ រួមមាន ខេត្តព្រៃវែង កំពង់ចាម កំពង់ឆ្នាំង កំពង់ស្ពឺ កណ្ដាល ត្បូងឃ្មុំ កំពង់ធំ  សៀមរាប បាត់ដំបង ឧត្ដរមានជ័យ ក្រចេះ និងខេត្តពោធិ៍សាត់។

គម្រោងសាងសង់ហេដ្ឋារចនាសម្ព័ន្ធដូចខាងក្រោម៖ ១) សាងសង់ស្ថានីយបូមទឹកបណ្ដែត និងបំពាក់ម៉ូទ័របង្កើនសម្ពាធទឹក ២) រៀបចំបណ្ដាញទុយោមេ ៣) សាងសង់រោង្គែរសម្រាប់បើកលាងកករជី និង ៤) ដំឡើងបណ្ដាញថាមពលសូឡា

១៥. យុត្តិកម្មលើគម្រោង (បង្ហាញពីហេតុផលថាហេតុអ្វីបានជាគម្រោងនេះត្រូវបានជ្រើសរើស)

ផលិតកម្មដំណាំបន្លែ

គឺជាប្រភេទដំណាំសំខាន់ទីពីរបន្ទាប់ពីស្រូវនៅក្នុងប្រទេសកម្ពុជាដែលផ្ដល់នូវប្រាក់ចំណូលជារៀងរាល់ឆ្នាំដល់ប្រជាកសិករខ្ពស់សម្រាប់ទ ្រទ្រង់ជីវភាពប្រចាំថ្ងៃ។ បច្ចុប្បន្ននេះ ប្រទេសកម្ពុជាមិនទាន់មានលទ្ធភាពផ្គត់ផ្គង់បន្លែដោយខ្លួនឯងបានគ្រប់គ្រាន់នៅឡើយទេ ដែលតម្រូវឱ្យមានការនាំចូលបន្លែមួយចំនួន (២០-៣០%) ដើម្បីបំពេញតម្រូវការបន្ថែមក្នុងស្រុក។ បច្ចុប្បន្ន ផ្ទៃដីផលិតកម្មដំណាំបន្លែបានកើនឡើងពី៥៦ ២២៨ហត នៅឆ្នាំ២០១៩ ដល់៧៦ ១៣៧ហត នៅឆ្នាំ២០២៣ និងទទួលបានបរិមាណផលបន្លែសរុបបានកើនឡើងពី៦៣៩ ៥១៣តោន នៅឆ្នាំ២០១៩ ដល់១ ០៦៥ ២២៧តោន នៅឆ្នាំ២០២៣។ ម៉្យាងវិញទៀត ផលិតកម្មដំណាំបន្លែនៅប្រទេសកម្ពុជាភាគច្រើនមានលក្ខណៈជាគ្រួសារ ដាំដុះតាមទម្លាប់ ពុំមានប្រភពទឹកគ្រប់គ្រាន់ និងដាំដុះតាម រដូវកាល។

ដើម្បីឆ្លើយតបទៅនឹងបញ្ហាខាងលើ ទាមទារឱ្យមានយន្តការគាំទ្របច្ចេកទេសចំពោះមុខមួយចំនួនដូចជា៖

- ជ្រើសរើសសហគមន៍ ឬក្រុមផលិតបន្លែដែលមានទីតាំងមានសក្ដានុពលដាំបន្លែ និងមានប្រភពទឹកគ្រប់គ្រាន់ ដើម្បីជំរុញផលិតកម្មបន្លែក្នុងទ្រង់ទ្រាយធំឱ្យបានពេញមួយឆ្នាំ
- ផ្គត់ផ្គង់គ្រាប់ពូជបន្លែ សម្ភារ: និងឧបករណ៍កសិកម្មចាំបាច់ដល់កសិករផលិតបន្លែ ជាពិសេសកសិករក្រីក្រខ្វះលទ្ធភាព
- ផ្ដល់បច្ចេកទេសទំនើប តាមរយៈការអនុវត្តកសិកម្មល្អប្រកបដោយភាពវៃឆ្លាតដើម្បីបង្កើនផលិតកម្មបន្លែសុវត្ថិភាព និងរៀបចំប្រតិទិនដាំដុះរបស់កសិករផលិតបន្លែសម្រាប់ផ្គត់ផ្គង់តាមតម្រូវការទីផ្សារ (កិច្ចសន្យា)
- ផ្ដល់ការណែនាំបច្ចេកទេសក្រោយពេលប្រមូលផល ការលាងសម្អាត ការវេចខ្ចប់ ការពិនិត្យគុណភាព និងសុវត្ថិភាពផលិតផលបន្លែ។

១៦. ផលប្រយោជន៍របស់គម្រោង (រៀបរាប់ពីអ្នកដែលនឹងទទួលប្រយោជន៍ផ្ទាល់និងមិនផ្ទាល់ពីការអនុវត្តគម្រោង)

- សហគមន៍កសិកម្មចំនួន៥ទីតាំង ក្នុងខេត្តគោលដៅចំនួន៤ខេត្ត នឹងទទួលបានហេដ្ឋារចនាសម្ព័ន្ធស្រោចស្រពបន្លែ
- កសិករចំនួន៦៤៩គ្រួសារ នឹងទទួលបានទឹកគ្រប់គ្រាន់ពេលមួយឆ្នាំ (ដាំបន្លែពី៤-៦ដង/ឆ្នាំ)

សម្រាប់ស្រោចស្រពបន្លែលើផ្ទៃដីប្រមាណ១៧១,៥៦ហិកតា និងរំពឹងថាទទួលបានបរិមាណផលបន្លែចំនួន១១ ១៥១,៤០តោន/ឆ្នាំ

- កសិករផលិតបន្លែអាចកាត់បន្ថយថ្លៃបូមទឹកនិងកម្លាំងពលកម្មស្រោចស្រពបន្លែចំនួន៦ ០០០ ០០០៛០០/ហត ក្នុង១ឆ្នាំជាមធ្យម

**១៧. ការសិក្សាសមិទ្ធិលទ្ធភាព**

តើគម្រោងនេះតម្រូវឲ្យមានការសិក្សាសមិទ្ធិលទ្ធភាពដែរ ឬទេ? **មាន**

ប្រសិនបើត្រូវការ តើការសិក្សាសមិទ្ធិលទ្ធភាព បានរៀបចំហើយឬនៅ? **មិនទាន់ចាប់ផ្តើម**

**១៨. ផលប៉ះពាល់ផ្នែកបរិស្ថាននិងសង្គម** (ពិពណ៌សង្ខេបពីផលប៉ះពាល់របស់គម្រោងលើប្រជាជននិងបរិស្ថានជុំវិញ ប្រសិនបើមាន។ តើគម្រោងនេះនឹងជួយដល់ការកាត់បន្ថយភាពក្រីក្រដែរឬទេ?)

**១៩. ការប្រែប្រួល អាកាសធាតុ**

ក. តើសកម្មភាព ឬធាតុចេញរបស់គម្រោងទាក់ ទងនឹងការប្រែប្រួលអាកាសធាតុ ឬទេ? **មាន**

ប្រសិនបើទាក់ទងនឹងការប្រែប្រួលអាកាស ធាតុ សូមជ្រើសរើស **ការបន្សាំ**

ខ. តើគម្រោងមានភាពទាក់ទងនឹងការប្រែប្រួលអាកាសធាតុកម្រិតណា?

សូមជ្រើសរើសវិស័យដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុរបស់គម្រោងនិងបំពេញការចូលរួមចំណែកនៃចំណាយដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុរបស់គម្រោងធៀបនឹងតម្លៃគម្រោងសរុប។

| វិស័យដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុ | ភាគរយ | ភាពទាក់ទងនឹងការប្រែប្រួលអាកាសធាតុ |
|---|---|---|

**២០. ការកាត់បន្ថយ ហានិភ័យ និង គ្រោះមហន្តរាយ**

តើសកម្មភាព ឬធាតុចេញរបស់គម្រោងទាក់ទងនឹងការកាត់បន្ថយហានិភ័យ និងគ្រោះមហន្តរាយដែរឬទេ? **មាន**

ប្រសិនបើ ទាក់ទងនឹងការកាត់បន្ថយហានិភ័យនិងគ្រោះមហន្តរាយ សូមជ្រើសរើស **ការត្រៀម**

**២១. ការវិភាគយេនឌ័រ** (តើគម្រោងនេះមានផលប៉ះពាល់ដល់តួនាទីរបស់បុរសនិងស្ត្រីក្នុងទីតាំងរបស់គម្រោងនេះដូចម្តេច? តើស្ត្រីនឹងត្រូវចូលរួមយ៉ាងសកម្មក្នុងការអនុវត្តគម្រោងនេះដែរឬទេ?)

**២២. សមត្ថភាពអនុវត្តគម្រោង** (តើក្រសួងមានជំនាញនិងបទពិសោធន៍គ្រប់គ្រាន់សម្រាប់អនុវត្តគម្រោងដែរឬទេ?)

**២៣. ស្ថានភាពនៃការអនុវត្តគម្រោង** (ពិពណ៌នាសង្ខេបអំពីវឌ្ឍនភាពរបស់គម្រោងនិងបង្ហាញអំពីភាពប្រឈមនានា ដែល បណ្តាលឲ្យមាន ការព្យាពេលក្នុងការអនុវត្តគម្រោង។)

ចាប់ពីឆ្នាំ២០២០ ដល់ឆ្នាំ២០២៤ គម្រោងបានសាងសង់ហេដ្ឋារចនាសម្ព័ន្ធស្រោចស្រពដំណាំបន្លែចំនួន ២៩កន្លែង តាមបណ្តុសហគមន៍កសិកម្មក្នុងខេត្តចំនួន១២ ដែលចំណាយថវិកាអស់ប្រមាណ ៧,៧ លានដុល្លារអាមេរិក។

**២៤. អាទិភាពរបស់គម្រោង** (បញ្ជាក់ពីការកំណត់អាទិភាពរបស់គម្រោងរបស់ក្រសួង ស្ថាប័ន)

2

**២៥. ការចូលរួមរបស់ដៃគូអភិវឌ្ឍ** (ផ្តល់ព័ត៌មានអំពីដៃគូអភិវឌ្ឍសក្តានុពល ដែលពាក់ព័ន្ធនឹងគម្រោងនេះ)

## ផ្នែក ខ ចំណាយរបស់គម្រោងនិងប្រភពហិរញ្ញប្បទាន

*(គិតជាពាន់ដុល្លារអាមេរិក)*

| ចំណាយវិនិយោគ | 2024 | | 2025 | 2026 | 2027 | 2028 | សរុប | ថវិកា |
|---|---|---|---|---|---|---|---|---|
| | ថវិកា | ដាក់ស្នើ | ថវិកា | ប៉ាន់ស្មាន | ប៉ាន់ស្មាន | ប៉ាន់ស្មាន | 2026-2028 | ចរន្ត |
| **ចំណាយប្រតិបត្តិ** | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | | | | |
| បៀវត្សរ៍ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| សម្ភារៈនិងរដ្ឋបាល | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| ផ្សេងៗ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | | | | |
| **ចំណាយមូលធន** | 7,700.0 | 7,700.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | | | | |
| ការសាងសង់ | 7,700.0 | 7,700.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| សេវាទីប្រឹក្សា | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| ទិញសម្ភារៈ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| ការបណ្តុះបណ្តាល | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| ផ្សេងៗ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | | | | |
| **ចំណាយសរុប** | 7,700.0 | 7,700.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | | | | |

| ប្រភពហិរញ្ញប្បទាន | 2024 | | 2025 | 2026 | 2027 | 2028 | សរុប | |
|---|---|---|---|---|---|---|---|---|
| | ថវិកា | ជាក់ស្តែង | ថវិកា | ប៉ាន់ស្មាន | ប៉ាន់ស្មាន | ប៉ាន់ស្មាន | 2026-2028 | |
| | | | | | | | | |
| ចំណូលពីគម្រោង | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| ថវិកាជាតិ | 7,700.0 | 7,700.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| សាច់ប្រាក់សុទ្ធ | 7,700.0 | 7,700.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| ធនធានផ្សេងៗ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| ហិរញ្ញប្បទាន របស់ ដៃគូអភិវឌ្ឍ | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| សរុបហិរញ្ញប្បទាន ដែលបានសន្យាផ្តល់ | 7,700.0 | 7,700.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| តម្រូវហិរញ្ញប្បទាន បំពេញបន្ថែម | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |

**បានឃើញ និង ឯកភាព**

**រដ្ឋមន្ត្រី**

កាលបរិច្ឆេទ: